# សម្ព័ន្ធភាពជាតិឃុំ-សង្កាត់កម្ពុជាទីក្រុងកំពតសង្កាត់ចោមចៅនិង ទួលសង្កែទទួលលិខិតសរសើរពីសហគមន៍អឺរ៉ុបនិងអង្គការខុនរ៉ាដ




*គណៈប្រតិភូកម្ពុជា ថតរូបអនុស្សាវរីយ៍ជាមួយម្ចាស់គម្រោងសហភាពអឺរ៉ុប និងអង្គការខុនរ៉ាដ (រូបថត:សុផល)*

**ភ្នំពេញ :** សម្ព័ន្ធភាពជាតិឃុំ-សង្កាត់កម្ពុជា ទីក្រុងកំពត សង្កាត់ចោមចៅ និងសង្កាត់ទួលសង្កែនៃព្រះរាជាណាចក្រកម្ពុជា បានទទួលការទទួលស្គាល់ និងលិខិតសរសើរពីសហគមន៍អឺរ៉ុប (EU) និងអង្គការខុនរ៉ាដអាដិនណៅអ៊ែរ លើគម្រោងការអនុវត្តន៍អភិបាលកិច្ចមូលដ្ឋានល្អ ការធ្វើឱ្យស្ថានភាពរស់នៅរបស់ប្រជាជនល្អប្រសើរ ការជួយទ្រទ្រង់បរិស្ថាន ការរៀបចំផ្សារ និងសណ្តាប់ធ្នាប់លក់ដូរតាមដងផ្លូវ ។

ពិធីប្រគល់រង្វាន់នេះបានធ្វើឡើងនៅក្នុងសន្និសីទចុងក្រោយនៃបណ្តាញគម្រោងភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋាននៅអាស៊ីអាគ្នេយ៍ (DELGOSEA) កាលពីថ្ងៃ៧-៨ខែសីហា ឆ្នាំ២០១២កន្លងទៅថ្មីៗនេះ នៅទីក្រុងបាងកកប្រទេសថៃ ។ សន្និសីទគម្រោង DELGOSEA ដែលផ្តល់មូលនិធិពីសហភាពអឺរ៉ុប និងមូលនិធិខុនរ៉ាដ-អាដិនណៅអ៊ែរនោះ មានអ្នកចូលរួមជាង១៥០នាក់ ដែលជាតំណាងដៃគូគម្រោងសមាគមរដ្ឋបាលមូលដ្ឋានបណ្តាទីក្រុងចូលរួមសាកល្បងអនុវត្តបទពិសោធន៍ល្អៗ ស្ថាប័នអប់រំ សារ-ព័ត៌មាន រដ្ឋាភិបាលថ្នាក់ជាតិ និងអង្គការសង្គមស៊ីវិលនានា ។ សម្ព័ន្ធភាពជាតិឃុំ-សង្កាត់នៃព្រះរាជាណាចក្រកម្ពុជាជាផ្នែកមួយនៃគម្រោង DEL-GOSEA នេះ ។

ជាមួយគ្នានោះដែរ លោកគង់ចាន់ថន លោកម៉ិន សុផានិត លោកឈឹម សុភាគ និងលោកប្រាក់ មុនី បានទទួលវិញ្ញាបនបត្រទទួលស្គាល់ជាគ្រូបង្គោលក្នុងការអនុវត្តន៍ និងបទ-ពិសោធន៍ល្អពីទីក្រុងសូឡូ(ឥណ្ឌូណេស៊ី) និងទីក្រុងម៉ារីគីណា (ហ្វីលីពីន) ។

លោក សក់ សេដ្ឋា រដ្ឋលេខាធិការក្រសួងមហាផ្ទៃនៃព្រះរាជាណា-ចក្រកម្ពុជា ក៏បានអញ្ជើញជាវាគ្មិននៅ

តទៅទំព័រ 85

# ក្លិបបាល់ទាត់ចម្ការកៅស៊ូបឹងកេត កំពុងតែធ្វើឱ្យគេចាប់អារម្មណ៍





តមកពីទំព័រ 01

## សម្ព័ន្ធភាពជាតិឃុំ...

ក្នុងសន្និសីទ DELGOSEA នោះដែរ និងមានការចូលរួមពីលោក សយ-កុសល ប្រធានសម្ព័ន្ធភាពជាតិឃុំ-សង្កាត់និង ជាចៅសង្កាត់ទួលសង្កែ លោកសុខ សាត ចៅសង្កាត់ចោមចៅ លោកអ៊ុក ខេមរា ចៅសង្កាត់រងទួលសង្កែ លោក នាក់ សុវណ្ណារី អភិបាលក្រុងកំពត លោកមិន មុនីមន្ត្រីសម្របសម្រួលថ្នាក់ជាតិនៃគម្រោងDELGOSEA ប្រចាំ កម្ពុជា ។

លោកនាក់ សុវណ្ណារី អភិបាលក្រុងកំពតដែលទទួលបានលិខិតសរសើរ បានថ្លែងថា សម្ព័ន្ធភាពជាតិឃុំ-សង្កាត់ បានជ្រើសរើសយកទីក្រុងកំពតជាទីក្រុងសាកល្បងសម្រាប់គម្រោងកែលម្អទីក្រុង ។ ក្រុងកំពតបានយកគំរូពីទីក្រុងម៉ារីគីណា ប្រទេសហ្វីលីពីន លើគម្រោងទ្រទ្រង់បរិស្ថាន(Eco-Saver)។

លោកបានបញ្ជាក់ថា ក្រោយពីអនុវត្តគម្រោងរយៈពេល៣២ខែ ក្រុងកំពតបានសម្រេចបានលទ្ធផលគួរឱ្យកត់សម្គាល់ ។ លទ្ធផលទី១-ការប្រមូលកាកសំណល់រឹង និងការញែកសំរាមបាន ត្រូវអនុវត្តនៅសាលារៀនគោលដៅចំនួន១៨ និងនៅប្រាំសង្កាត់។ ទី២-ពង្រីកការផ្សព្វផ្សាយ និងបញ្ជ្រាបការយល់ដឹងដល់ប្រជាពលរដ្ឋពី ២.០០០គ្រួសារដល់ជាង៥.០០០គ្រួសារ ។ ប្រជាជន៧៥ភាគរយបានប្រើប្រាស់ទឹកស្អាត និង៦៧ភាគរយមានបង្គន់អនាម័យ ។ ទី៣-មន្ត្រីក្រុងកំពតបីនាក់ បានទទួលការបណ្តុះបណ្តាលអំពីបរិស្ថាននៅហ្វីលីពីន និង១៣នាក់នៅប្រទេសថៃ ចំណែក២២នាក់ទៀតទទួលការបណ្តុះបណ្តាលអំពីជំនាញដោះស្រាយជម្លោះ ។ ទី៤-ដើមឈើចំនួន៥១១ដើមបានត្រូវដាំនៅតាមផ្លូវ៤៦៧០ ដាំនៅតាមស្ថាប័នសាធារណៈនិង៣៤៧ដើម នៅតាមសហគមន៍។ ក្រៅពីនេះមានការកែលម្អបរិស្ថានជុំសជុល និងស្ថាបនាថ្មីនូវកន្លែងសាធារណៈមួយចំនួនដូចជាមាត់សមុទ្រសួនច្បារជាដើម ។

លោកសុខ សាត ចៅសង្កាត់ចោមចៅ បានឱ្យដឹងថា សង្កាត់ចោមចៅជាផ្នែកមួយនៃគម្រោងភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋាននៅអាស៊ីអាគ្នេយ៍ ។ លោកបានទទួលលិខិតសរសើរពីសហគមន៍អឺរ៉ុប និងអង្គការខុនរ៉ាដលើគម្រោងរៀបចំផ្សារ និងការលក់ដូរអនាធិបតេយ្យនៅតាមដងផ្លូវនៅក្នុងសង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ ។ គម្រោងនេះ កម្ពុជាយើងយកគំរូពីទីក្រុងសូឡូ ប្រទេសឥណ្ឌូណេស៊ី ។ គម្រោងនេះ ការរៀបចំរបនាសម្ព័ន្ធដូចជា ការដាក់លូកុំឱ្យទឹកលិចរៀបចំផ្សារ និងកន្លែងលក់ដូរអនាធិបតេយ្យតាមដងផ្លូវ ដើម្បីជួយសម្រួលកុំឱ្យស្ទះនិងគ្រោះថ្នាក់ចរាចរណ៍ ព្រោះក្នុងសង្កាត់នេះមានរោងចក្រជាង១០០កន្លែង ។

លោកសយ កុសលប្រធានសម្ព័ន្ធភាពជាតិឃុំ-សង្កាត់ បានឱ្យដឹងថា សម្ព័ន្ធភាពជាតិឃុំ-សង្កាត់នៃព្រះរាជាណាចក្រកម្ពុជា ជាសមាជិកមួយនៅក្នុងគម្រោងអភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យនៅអាស៊ីអាគ្នេយ៍រួមជាមួយនឹងប្រទេសបួនផ្សេងទៀត គឺវៀតណាម ថៃ ឥណ្ឌូណេស៊ី និងហ្វីលីពីន ។ គម្រោងនេះមានរយៈពេល៣២ខែ ដែលចាប់ផ្តើមនៅថ្ងៃទី១ខែមីនាឆ្នាំ២០១០ ហើយនិងបញ្ចប់នៅថ្ងៃទី៣១ខែសីហាឆ្នាំ២០១២ ដោយទទួលថវិកា ពីសហភាពអឺរ៉ុប និងខុនរ៉ាដ ចំនួន១,៨លានអឺរ៉ូ ។

សម្ព័ន្ធភាពជាតិឃុំសង្កាត់ ចូលរួមក្នុងការអនុវត្តន៍គម្រោង ដូចជាការស្វែងរកការគាំទ្ររបស់ស្ថាប័នពាក់ព័ន្ធពិសេសក្រសួងមហាផ្ទៃដល់ការអនុវត្តន៍សកម្មភាពរបស់គម្រោង នៅក្រុងបាត់ដំបង ក្រុងកំពត សង្កាត់ទួលសង្កែ និងសង្កាត់ចោមចៅរាជធានីភ្នំពេញ ព្រមទាំងផ្សព្វផ្សាយអំពីការអនុវត្តន៍ល្អៗរបស់គម្រោង និងអំពីអភិបាលកិច្ចមូលដ្ឋានល្អ។

លោក មិន មុនី អ្នកសម្របសម្រួលថ្នាក់ជាតិនៃគម្រោង DELGOSEA បានឱ្យដឹងថា ក្រៅពីទីក្រុងកំពត និងសង្កាត់ចោមចៅរបស់កម្ពុជាឥណ្ឌូណេស៊ី មានទីក្រុង៤ស្ថិត នៅក្នុងគម្រោង DELGOSEA ហ្វីលីពីនមាន៣ទីក្រុង ថៃមាន៤និងវៀតណាមមាន៣ទីក្រុង។ ដៃគូអនុវត្តគម្រោងរួមមានសមាគមនៃទីក្រុងវៀតណាម(ACVN)សម្ព័ន្ធភាពជាតិឃុំ សង្កាត់នៃព្រះរាជាណាចក្រកម្ពុជា(NLC/S) មូលនិធិអភិវឌ្ឍន៍រដ្ឋាភិបាលមូលដ្ឋាននៃប្រទេសហ្វីលីពីន( LOGODEF) វិទ្យាស្ថានបរិស្ថាននៃប្រទេសថៃ(TEI) និងសហព័ន្ធទីក្រុងនិងរដ្ឋាភិបាលមូលដ្ឋាននៅអាស៊ីប៉ាស៊ីហ្វិក(UCLG ASPAC) ។

លោកបានបញ្ជាក់ថា ទោះគម្រោង DELGOSEA បានបញ្ចប់ក្តី តែដៃគូគម្រោងទាំង៥ប្រទេស បានសន្យានឹងបន្តទំនាក់ទំនងគ្នា ផ្លាស់ប្តូរបទពិសោធន៍ទាក់ទងនឹងការអនុវត្តន៍ល្អ និងអភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យ។

អ្នកស្រី ស៊ូហ្សាន ស្តេហ្វាន (Susanne Stephan) នាយកគម្រោង DELGOSEA បានមានប្រសាសន៍ថា កិច្ចសហប្រតិបត្តិការ ស្តីពីអភិបាលកិច្ចមូលដ្ឋាននេះមានគោលបំណង ធានាឱ្យមានស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋក្នុងប្រទេសអាស៊ីភាគអាគ្នេយ៍បានប្រសើរឡើង និងការគាំទ្រដល់អភិក្រមរួមគ្នារវាងប្រទេសជាសមាជិកក៏កំពុងតែរីកចម្រើនផងដែរ។ លោកស្រីបានបញ្ជាក់ថា "សន្និសីទចុងក្រោយនេះ មិនមែនជាដំណាក់កាលបញ្ចប់នោះទេ គ្រាន់តែជាការបញ្ចប់ជំពូកមួយ និងចាប់ផ្តើមជំពូកថ្មីមួយតែប៉ុណ្ណោះ។ សន្និសីទនេះជាឱកាស ដើម្បីពិនិត្យមើលនូវអ្វីដែលសម្រេចបាន និងពិភាក្សាលើផែនទីបង្ហាញផ្លូវសម្រាប់ការរៀនសូត្របន្ថែមទៀតនិងផ្លាស់ប្តូររវាងរដ្ឋបាលមូលដ្ឋាននៅអាស៊ីអាគ្នេយ៍ ក៏ដូចជាពង្រឹងនូវតួនាទីរបស់ខ្លួនក្នុងកម្រិតថ្នាក់តំបន់នាពេលអនាគត ។

លោកបណ្ឌិតផេតធ័រ ខូភីងហ្គ័រ (Peter Koppinger) នាយកគម្រោង DELGOSEA និងជាតំណាងអង្គការខុនរ៉ាដប្រចាំប្រទេសហ្វីលីពីន បានឱ្យដឹងថា ប្រជាជនជិត៤០០០០នាក់ បានទទួលផលប្រយោជន៍ពីគម្រោង Delgosea។

លោកបានបន្តថា ភាពជាដៃគូសម្រាប់អភិបាលកិច្ចមូលដ្ឋានតាមបែបប្រជាធិបតេយ្យ នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ បង្កើតបណ្តាញ៣២ទីក្រុង និងខេត្តនានាដើម្បីអនុវត្តតាមការអនុវត្តន៍ល្អនៃអភិបាលកិច្ចអន្តរតំបន់ទៅដល់ប្រទេសជាដៃគូនានាដូចជា កម្ពុជា ឥណ្ឌូណេស៊ី ហ្វីលីពីន ថៃ និងវៀតណាម។ បណ្តាញនេះត្រូវបានគាំទ្រដោយសមាគមរដ្ឋាភិបាលមូលដ្ឋានចំនួន១១គ្រូបង្គោល៧៥នាក់ តំណាងរដ្ឋអំណាចមូលដ្ឋានអង្គការមិនមែនរដ្ឋាភិបាល វិទ្យាស្ថានអប់រំ និងបណ្តាញសារព័ត៌មាននានាចំនួន១៣០០នាក់ និងគាំទ្រតួនាទីក្នុងការផ្តល់ឱ្យ និងជួយដល់ការផ្ទេរ និងនិរន្តរភាពនៃការអនុវត្តន៍ តាមការអនុវត្តន៍ល្អនៃអភិបាលកិច្ចមូលដ្ឋាន និងត្រូវបានគ្រប់គ្រងដោយអង្គការខុនរ៉ាដ Konrad-Adenauer-Stiftung (KAS)សហការ ឧបត្ថម្ភដោយសហភាពអឺរ៉ុប នៃប្រទេសអាល្លឺម៉ង់តាមរយៈក្រសួងសហប្រតិបត្តិការ អភិវឌ្ឍន៍ប្រទេសអាល្លឺម៉ង់ ៕ **សុផល**




លោកមិន មុនី ទទួលបានលិខិតសរសើរ ក្នុងនាមជាអ្នកសម្របសម្រួលឆ្នើមដែលបានខិតខំប្រឹង-ប្រែងប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ក្នុងការសម្របសម្រួលគម្រោង DELGOSEA ប្រចាំកម្ពុជា



គណៈប្រតិភូកម្ពុជាចូលរួមក្នុង-សន្និសីទ Delogosea (រូបៈសុផល)